ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អូរលុង
# សម្រាប់រយៈពេល ៣ ឆ្នាំ
## ( កក្កដា ២០១៩ - មិថុនា ២០២២ )

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | អូរលុង |
| ភូមិ | ៖ | អូរលុង ដីដុះលើ ដីដុះក្រោម ព្រៃគូរ ព្រែកប្រសព្វកណ្តាល ព្រែកប្រសព្វក្រោម និងបឹងលាច |
| ឃុំ | ៖ | ព្រែកប្រសព្វ |
| ស្រុក | ៖ | ព្រែកប្រសព្វ |
| ខេត្ត | ៖ | ក្រចេះ |

**ខែមករា ឆ្នាំ២០១៩**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អូរលុង
# សម្រាប់រយៈពេល ៣ ឆ្នាំ
## ( កក្កដា ២០១៩ - មិថុនា ២០២២ )

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | អូរលុង |
| ភូមិ | ៖ | អូរលុង ដីដុះលើ ដីដុះក្រោម ព្រៃគូរ ព្រែកប្រសព្វកណ្ដាល ព្រែកប្រសព្វក្រោម និងបឹងលាច |
| ឃុំ | ៖ | ព្រែកប្រសព្វ |
| ស្រុក | ៖ | ព្រែកប្រសព្វ |
| ខេត្ត | ៖ | ក្រចេះ |

**ខែមករា ឆ្នាំ២០១៩**

## មាតិកា


១. ស្ថានភាពទូទៅ ... ៣
២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ... ៤
ក. ប្រជាពលរដ្ឋ ... ៤
ខ. មុខរបរ ... ៤
៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ ... ៥
ក. ទីតាំង ... ៥
ខ. ដែននេសាទ ... ៥
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ... ៦
ឃ. ធនធានជលផល ... ៦
៤. ការធ្វើនេសាទ ... ៧
ក. អ្នកនេសាទ ... ៧
ខ. ឧបករណ៍នេសាទ ... ៧
គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ... ៨
៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ... ៨
ក.ទស្សនៈវិស័យ ... ៨
ខ. គោលបំណងរួម ... ៨
គ. គោលបំណងជាក់លាក់ ... ៨
ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ... ៩
ឃ.១. ធនធានជលផល និងអេកូឡូស៊ី ... ៩
ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ ... ១១
ឃ.៣. ការគ្រប់គ្រង ... ១៣
ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ... ១៦
ច. យុទ្ធសាស្ត្រ ... ១៦
តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អូរលុងរយៈពេល ៣ ឆ្នាំ (២០១៩-២០២២) ... ១៨
តារាងកម្មវិធីការងារប្រចាំឆ្នាំ (កក្កដា ២០១៩-មិថុនា ២០២២) ... ២៦

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទអូរលុង មានទីតាំងគ្របដណ្ដប់ភូមិចំនួន៧ រួមមានភូមិអូរលុង ដីដុះលើ ដីដុះក្រោម ព្រៃគួរ ព្រែកប្រសព្វកណ្ដាល ព្រែកប្រសព្វក្រោម និងបឹងលាច ដែលស្ថិតនៅក្នុងឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ សហគមន៍នេសាទអូរលុង ត្រូវបានបង្កើតឡើងជាផ្លូវការដោយមហាសន្និបាតកំណើតដំបូងប្រារព្ធធ្វើនៅឆ្នាំ២០០៤ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រវាងនាយខណ្ឌរដ្ឋបាលជលផលក្រចេះ និងប្រធានគណៈកម្មការសហគមន៍នេសាទនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩។ សហគមន៍នេសាទនេះ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយប្រកាសលេខ ៥៧៩ ប្រក.កសក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមការសម្របសម្រួល និងគាំទ្រផ្នែកបច្ចេកទេសពីខណ្ឌរដ្ឋបាលជលផលក្រចេះ។ យោងតាមភាពចាំបាច់របស់សហគមន៍នេសាទ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (ដំណាក់កាលទី៣) សមាសភាគទី១ ដែលអនុវត្តដោយខណ្ឌរដ្ឋបាលក្រចេះ បានជួយសម្របសម្រួលធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ហើយតាមការធ្វើបច្ចុប្បន្នភាព សមាជិកដែលបានចុះក្នុងបញ្ជីជាផ្លូវការ សរុបចំនួន១៨៩ នាក់ ស្រីមានចំនួន៧០ នាក់ ក្នុងនោះគ្រួសារសរុបមានចំនួន១៨៥ គ្រួសារ។ ដោយសារគណៈកម្មការផុតអាណត្តិ និងតបតាមការស្នើសុំរបស់អាជ្ញាធរស្រុក សហគមន៍នេសាទបានរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញ នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៨។ គណៈកម្មការសហគមន៍នេសាទអូរលុងដែលទើបជាប់ឆ្នោតថ្មីមានចំនួន១១ នាក់ ក្នុងនោះស្ត្រីមានចំនួន ១ នាក់។

កន្លងមកសហគមន៍នេសាទបានអនុវត្តសកម្មភាពសំខាន់ៗ មានដូចជា ការរៀបចំបញ្ជីឈ្មោះ និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ការចូលរួមកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ ការរៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទ ការរៀបចំក្រុមល្បាត ការចូលរួមវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលា។ ម្យ៉ាងវិញទៀត ការងារចុះល្បាតជាប្រចាំក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលដែលកើតមាននៅក្នុងកន្លែងនេសាទសហគមន៍ ដោយសហការជាមួយសមត្ថកិច្ចជលផល មន្ទីរបរិស្ថាន អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។ រហូតមកដល់បច្ចុប្បន្នសហគមន៍នេសាទមានការរីកចម្រើន ដោយទទួលបានភាពជោគជ័យក្នុងការកាត់បន្ថយការកាប់បំផ្លាញព្រៃលិចទឹក និងបានកាត់បន្ថយសកម្មភាពបទល្មើសនេសាទនានាដែលធ្វើឱ្យផលនេសាទមានការកើនឡើង។ ទន្ទឹមនឹងនេះ ដោយសារតែអ្នកភូមិមានការយល់ដឹង ការចូលរួមពីសហគមន៍ និងតម្រូវការធនធានធម្មជាតិ ជាពិសេសធនធានជលផល។

ទោះបីទទួលបានលទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅជួបប្រទះនូវបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រង៖

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី រួមមានការកាប់បំផ្លាញព្រៃលិចទឹក ត្រីខ្វះជម្រកពងកូន ការបង្ហូរសំណល់រាវ និងសំណល់រឹងចូលក្នុងបឹងបួ និងការបាត់បង់ត្រីពូជមួយចំនួនដូចជាត្រីគល់រាំង ត្រីប្រា ត្រីក្រសក់ ត្រីប្រម៉ា ត្រីព្រួលជាដើម

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមានខ្វះដើមទុនប្រកបមុខរបរ គ្មានជំនាញច្បាស់លាស់ក្នុងការប្រកបរបរចិញ្ចឹមជីវិត ខ្វះមធ្យោបាយលក់ផលិតផល ខ្វះទឹកស្រោចស្រពធ្វើដំណាំកសិកម្ម ខ្វះជំនាញចិញ្ចឹមត្រី ប្រាក់ចំណូលទាប ចំណេះដឹងនៅមានកម្រិត ខ្វះមុខរបរនិងការងារ ទីតាំងភូមិឆ្ងាយពីទីប្រជុំជនឆ្ងាយពីមណ្ឌលសុខភាព ផ្លូវពិបាកធ្វើដំណើរ និងការធ្វើចំណាកស្រុកទៅរកការងារធ្វើ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមានការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ឧបករណ៍នេសាទទំនើប ខ្វះសម្ភារ និងមធ្យោបាយបង្ក្រាបបទល្មើសនេសាទ សមត្ថភាពគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ និងការសហការជាមួយអ្នកពាក់ព័ន្ធនៅមានកម្រិត ប្រជាពលរដ្ឋខ្វះការយល់ដឹងពីច្បាប់ស្តីពីជលផល ខ្វះការចូលរួមពីប្រជាពលរដ្ឋក្នុងការអភិរក្ស និងទប់ស្កាត់បទល្មើសនេសាទ សមាជិកសហគមន៍យល់ថាការងាររបស់គណៈកម្មការជាតួនាទីរបស់បុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ធ្វើការងារផ្ទះ និងលក់ដូរប៉ុណ្ណោះ ហើយទោះបីស្ត្រីមានការចូលរួមក្នុងកិច្ចប្រជុំនានាមានចំនួនច្រើន ប៉ុន្តែការសម្រេចនៅមានកម្រិត។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មាន ៨.៥០៨នាក់ ស្រី៤.៣៧៣នាក់-ជាជនជាតិខ្មែរ ១០០%។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមាន ១០០%។

ប្រជាពលរដ្ឋក្នុងសហគមន៍ មានស្ថានភាពដូចខាងក្រោម ៖

- ចំនួនស្ត្រីមេម៉ាយមាន ៣១៥ នាក់
- ចំនួនជនពិការមាន ៦៤ នាក់ ស្រី ២៥
- ចំនួនចាស់ជរាមាន ១៩៥ នាក់ ស្រី ១០៧ នាក់
- ចំនួនកុមារកំព្រាមាន ១៩ នាក់ ស្រី ៩ នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងមាន ៦៨ នាក់ ស្រី ៤៣ នាក់
- កម្រិតសិក្សាអប់រំរួមមាន អ្នកមិនចេះអក្សរមានចំនួន៩៨នាក់ ស្រី៥៨នាក់ ថ្នាក់បឋមសិក្សាចំនួនសរុប ៩៩៤នាក់ ស្រី៥៦០នាក់ មធ្យមសិក្សាចំនួនសរុប៣២៧នាក់ ស្រី១៩៥នាក់ និងថ្នាក់ឧត្តមសិក្សាចំនួនសរុប១០៣នាក់ ស្រី៥៤នាក់។

### ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន ៖

- ធ្វើនេសាទជាលក្ខណៈគ្រួសារចំនួន ១.០២០ គ្រួសារ
- ធ្វើស្រែវស្សាចំនួន១.០៨០ គ្រួសារ
- ដាំបន្លែចំនួន២៩ គ្រួសារ ទំហំ២១ ហិកតា
- ធ្វើចំការចំនួន២០៥ គ្រួសារ ទំហំ៦១ ហិកតា

- ធ្វើជាងផ្ទះចំនួន២៨ នាក់
- ធ្វើជាងទូកចំនួន០៤ នាក់
- ធ្វើកម្មករនៅពេលទំនេរពីការងារធ្វើស្រែចំនួន៤៥ %
- លក់ដូរចំនួន១៣៩ គ្រួសារ
- មន្ត្រី បុគ្គលិក កម្មករក្របខ័ណ្ឌរដ្ឋចំនួន២១៤ នាក់
- បំរើការងារក្រុមហ៊ុនរោងចក្រចំនួន៦២៤នាក់ ស្រី៣៣៨ នាក់។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

### ក. ទីតាំង

កន្លែងនេសាទសហគមន៍អូរលុង ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍អូរលុងមានទំហំ៣.៨៧៣ ហិកតា និងមាននិយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងជាប់ព្រំប្រទល់ភូមិព្រែកប្រសព្វកណ្តាល ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ
- ខាងត្បូងជាប់ភូមិដីដុះក្រោម ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ
- ខាងកើតជាប់ទន្លេមេគង្គ ឃុំព្រែកសាម៉ាន់ និងឃុំកញ្ជរ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ
- ខាងលិចជាប់ភូមិបឹងលាច ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍អូរលុង ស្ថិតនៅតាមបឹង ព្រែក ត្រពាំង និងប្រឡាយ ។ កន្លែងនេសាទសហគមន៍អូរលុងមានបឹងចំនួន១៣ ត្រពាំងចំនួន៧ ព្រែកចំនួន៦ និងប្រឡាយចំនួន១ ៖

| | | |
|---|---|---|
| - បឹងផ្តាំ | ទំហំ៣៥ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - បឹងជ្វា | ទំហំ១៥០ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - បឹងព្រះទន្លេ | ទំហំ១២០ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - បឹងរឡាំ | ទំហំ៣០ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - បឹងពើក | ទំហំ២០ហិកតា | មានទឹកពេញមួយឆ្នាំ |
| - បឹងកៀនឈ្លូស | ទំហំ៨ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - បឹងក្បូន | ទំហំ៣ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - បឹងវែង | ទំហំ៧ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - បឹងស្បូវ | ទំហំ៣ ហិកតា | មានទឹកពេញមួយឆ្នាំ |

| | | |
|---|---|---|
| - បឹងរ៉ៃ | ទំហំ២ ហិកតា | មានទឹកពីខែឧសភាដល់កុម្ភៈ |
| - បឹងកក់ | ទំហំ៥ ហិកតា | មានទឹកពីខែឧសភាដល់កុម្ភៈ |
| - បឹងក្រចាប់ | ទំហំ១៥ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - បឹងរាំងទ្រមែ | ទំហំ៣ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - ត្រពាំងបាក់ជាវ | ទំហំ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - ត្រពាំងបាក់ដោក | ទំហំ១ ហិកតា | មានទឹកពីខែឧសភាដល់មីនា |
| - ត្រពាំងកាផាច | ទំហំ១ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - ត្រពាំងឫស្សី | ទំហំ៤ ហិកតា | មានទឹកពីខែឧសភាដល់មីនា |
| - ត្រពាំងម្រុំ | ទំហំ២ ហិកតា | មានទឹកពីខែឧសភាដល់មីនា |
| - ត្រពាំងទឹកខ្មេះ | ទំហំ ១ ហិកតា | មានទឹកពីខែឧសភាដល់មីនា |
| - ត្រពាំងក្រាញ់ | ទំហំ ៦ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - ព្រែកទទឹង | ប្រវែង៣០ ម៉ែត្រ | មានទឹកពីខែឧសភាដល់មីនា |
| - ព្រែកតាឃុត | ប្រវែង១០០ ម៉ែត្រ | មានទឹកពីខែសីហាដល់កុម្ភៈ |
| - ព្រែកសណ្ដាន់ | ប្រវែង៣០០ ម៉ែត្រ | មានទឹកពេញមួយឆ្នាំ |
| - ព្រែកតាបោយ | ប្រវែង៤.០០០ ម៉ែត្រ | មានទឹកពីខែសីហាដល់មករា |
| - ព្រែកតាឡុក | ប្រវែង៣០០ ម៉ែត្រ | មានទឹកពេញមួយឆ្នាំ |
| - ព្រែកធំ | ប្រវែង២០០ ម៉ែត្រ | មានទឹកពេញមួយឆ្នាំ |
| - ប្រឡាយបឹងលាច | ប្រវែង៧.០០០ម៉ែត្រ | មានទឹកពេញមួយឆ្នាំ |

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

សមាជិកសហគមន៍បានឯកភាពគ្នាកំណត់យកអន្លង់ក្នុងបឹងចំនួន២ ដែលមានសក្ដានុពលជាកន្លែងអភិរក្សត្រីមេពូជគឺ អន្លង់ក្នុងបឹងផ្ដាំ ទំហំ៤ ហិកតា (បណ្ដោយ២០០ម ទទឹង២០០ម) និង អន្លង់ក្នុងបឹងថ្លា ទំហំ៦ ហិកតា (បណ្ដោយ៣០០ម ទទឹង២០០ម) ។

**ឃ. ធនធានជលផល**

**ឃ.១. ប្រភេទត្រី ៖**

ត្រីរ៉ស់ ព្រួល ប្រា ឆ្ដោ ឆ្លាំង កេស ឆ្ដោក ក្អែក តានេល ត្រសក់ គល់រាំង ខ្យា រៀល ខ្លា កញ្ចុះ លិញ ក្រាញ់ ចង្វារ ផ្ទោង ឆ្លូញ ពោ អាចម៍កុក ស្លឹកឫស្សី កន្ត្រប់ ភ្លាំងហាយ ខ្នាន់ កន្ធរ ក្រឡង់ សណ្ដាយ អណ្ដែង ដំរី តាអោន ក្រម៉ម ស្លាត កំភ្លៀវ ខ្ញឹង កញ្ជនជ័យ រមាស ក្រុំ ផ្កាស្នោ ឈ្មៀត កញ្ជ្រូក បណ្ដូលអំពៅ ច្រកែង កាហែ ក្រឹម ក្រឹមទន្សាយ ស្រកាក្ដាម លលកស ឆ្ពិន ជញ្ជក់ បណ្ដូលចេក កំពិស កំពត ក្រពាត់ ក្រុះ បង្គួយ កញ្ជាញ់ច្រាស ។ល។

ឃ.២. ប្រភេទវារីសត្វ ៖

អណ្តើក ពស់ ខ្យង ក្តាម អន្ទង់ ខ្ចៅ កង្កែប កន្ធាយ ឈ្លើង គ្រុំ លាស ។ល។

ឃ.៣. ព្រៃលិចទឹក និងវារីរុក្ខជាតិ

ថ្លើមអណ្តើក អួយយ៉ាស់ (បន្លាយូន) បន្លាស្អិត រាំង ប្របួយមេ ប្របួយឈ្មោល ស្បាត ភ្នំភ្លើង អញ្ចាញ កន្សែង ស្នែងក្របី កន្ទៀវ ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្វាង ត្នួ ខ្នាយមាន់ វល្លិ៍ប្រេង វល្លិ៍ទឹកដោះ វល្លិ៍ត្រដិត វល្លិ៍ដោះគន់ វល្លិ៍ត្រី វល្លិ៍ត្តើក ល្ពាក់ទឹក ស្លាបទា កន្ទាំងហៃ រញា ស្ទោ ស្លត់ បន្លាឃ្លេផ្តោល ថ្វាន់ ស្នួលទឹក ច្រកែង ប្រផែង ផ្តៅ ក្អែកព្រាប នៃប៉ូវ បាក់ដង ត្រដក់ ល្មៀង កន្ទុយអន្ទង់ ពោះក្អម ក្រចៅ វល្លិ៍អណ្តាតត្រកួត ក្រចាប់ សារាយសាប សារាយជូរ កំប្លោក ចកតូច ចកធំ ចកបាយទា កំពីងពួយស កំពីងពួយក្រហម ត្រកួន ព្រលិតអាចម៍មាន់ ព្រលិតដូង រំចង់ ស្គន់អំបោះ ត្រាវអណ្តែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំប្លង កក់ជ្រុង កក់ក្តាម ឈូក ចន្ទល់ភ្នំ (វល្លិ៍ថ្គាល់ត្រី) កញ្ឆែត ស្មៅថ្នក់ទឹក ស្គន់ដំរី ។ល។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១៨៦ នាក់ ស្រី៦៩ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន៩១ នាក់ ស្រី៣០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៧៦ នាក់ ស្រី៣៨ នាក់។

ខ. ឧបករណ៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ ឧបករណ៍ នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | |
| មង | ដៃ (៨០ម) | ៣០០ | ២០០ | ៧០ | ក្រឡា ២,៥ ស.មឡើង | ក្រឡា ២,៥ ស.មឡើង | ក្រឡា ២,៥ ស.មឡើង | មករា ដល់ ធ្នូ |
| សន្ទូច | ផ្លែ | ៤០.០០០ | ១០.០០០ | ២០.០០០ | ផ្លែលេខ ១៩-២០ | ផ្លែលេខ ១៩-២០ | ផ្លែលេខ ១៩-២០ | កក្កដា ដល់ វិច្ឆិកា |
| លប ប្រឹសបក់ | គ្រឿង | ៣.៦០០ | ៣.៦០០ | | ទំហំ០,៣មx ០,៨ម ក្រឡា ២ស.មឡើង | ទំហំ០,៣មx ០,៨ម ក្រឡា ២ស.មឡើង | | មករា ដល់ ធ្នូ |
| លាន់ អន្ទង់ | គ្រឿង | ៣.៧៨០ | ៣.៥០០ | ៤២០ | ទំហំ០,០៨ម x១,៥ម | ទំហំ០,០៨ម x១,៥ម | ទំហំ០,០៨ មx១,៥ម | មករា ដល់ ធ្នូ |
| អួន | វង់ (៨០ម) | | | ៤ | | | | មិនាដល់ឧសភា |

| ប្រភេទទូកកាណូត | ចំនួន | | | ចំណុះ | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកចែវ | ៩០ ទូក | ៦០ ទូក | ២០ ទូក | ៣០០គ.ក្រ | ៣០០ គ.ក្រ | ២០០ គ.ក្រ | | | |
| ទូកម៉ាស៊ីន | ១០ | ៣៧ | ១៥ | ៥០០គ.ក្រ | ៥០០គ.ក្រ | ៥០០គ.ក្រ | ៦សេះ | ៦សេះ | ៦សេះ |

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៣៧៩.៣០គ.ក្រ | ៥៨៦.៨៦ គ.ក្រ | ៩១៦.១៦ គ.ក្រ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទអូរលុង មានទស្សនវិស័យចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ។

គ. គោលបំណងជាក់លាក់

- ការពារ និងដាំព្រៃលិចទឹកជាជម្រកត្រីនៅតាមច្រាំងទន្លេ
- បង្កើនជម្រើសមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ តាមរយៈការចិញ្ចឹមសត្វ ត្រី ដាំបន្លែ អេកូទេសចរ និងមានទីផ្សារសម្រាប់កសិផល
- កាត់បន្ថយបទល្មើសនេសាទ តាមរយៈការផ្សព្វផ្សាយ និងចុះល្បាត ដោយមានកិច្ចសហការជាមួយ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ។

## ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ឃ.១. ធនធានជលផល និងអេកូឡូស៊ី

#### ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ការប៉ាន់ស្មានថវិកា(ដុល្លារ) |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ / ប្រវែង | ចំនួន | |
| នៅតាមដងទន្លេមេគង្គ បឹង អូរ ព្រែកនិងត្រពាំងទាំងឡាយ នៅខាងក្រៅអន្លង់អភិរក្សសហគមន៍ | ពេញមួយឆ្នាំ | មង | ក្រឡា២,៥ស.មឡើង | ១២០គ្រួសារx២៤០ម/គ្រួសារ | ១៥០ (៥០/ឆ្នាំ សម្រាប់ការងារផ្សព្វផ្សាយ) |
| | | សន្ទូច | លេខ១៩ដល់លេខ២០ | ៧៥គ្រួសារx៤០០ផ្លែ/គ្រួសារ | |
| | | លបប្រើសបក់ | ០,៣មx០,៨ម | ៧៥គ្រួសារx៤០គ្រឿង/គ្រួសារ | |
| | | លាន់អន្ទង់ | ០,០៨មx១,៥ម | ៤៥គ្រួសារx៥០គ្រឿង/គ្រួសារ | |

#### ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់ក្នុងបឹងផ្គាំ | ៤ ហិកតា | • ត្រីគ្រប់ប្រភេទ<br>• សត្វទឹកគ្រប់ប្រភេទ<br>• រុក្ខព្រៃលិចទឹកគ្រប់ប្រភេទ | • ដាក់ពោង និងស្លាកសញ្ញាតាមអន្លង់<br>• ទម្លាក់លូសិប្បនិម្មិត<br>• តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស<br>• លែងកូនត្រីពូជ | • ដាក់ពោង/លូសិប្បនិម្មិត (៣០០x ១០= ៣.០០០)<br>• តម្លើងផ្ទាំងផ្សព្វផ្សាយ(២x ២០០=៤០០)<br>• លែងកូនត្រី (៣ លើកx ៥០០= ១.៥០០) | កក្កដា ២០១៩ | មិថុនា ២០២២ |
| អន្លង់ក្នុងបឹងផ្កា | ៦ ហិកតា | | | | | |

### ឃ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ / ទីតាំង | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| -អូរថ្ម ភូមិជីដុះក្រោម<br>-ផ្លូវដើមសំរោងភូមិអូរលុង<br>-ទួលយាយចើប ភូមិបឹងលាច<br>-ទួលវិហារ ភូមិព្រែកប្រសព្វកណ្ដាល<br>-ប្រឡាយអូរតាឡាន់ភូមិព្រែគូ<br>-ផ្លូវទំនប់ព្រែកចិន ភូមិអូរលុង | បោះបង្គោលព្រំប្រទល់កន្លែងនេសាទ | ៦ បង្គោល (លើគោក) | ៦x៣០០= ១.៨០០ | កក្កដា ២០១៩ | ធ្នូ ២០១៩ |
| | រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ (ឱ្យស្ត្រីនិងបុរសជាគណៈកម្មាការសហគមន៍នេសាទចូលរួមសម្រេចចិត្តក្នុងការកំណត់ទីតាំងបោះបង្គោលព្រំប្រទល់) | ១ ផ្ទាំង | ៣០០ | តុលា ២០១៩ | ធ្នូ ២០១៩ |

### ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ / ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ព្រៃលិចទឹកនៅជុំវិញបឹងផ្ដាំ និងបឹងថ្លា | ២៥០ហិកតា | ព្រៃលិចទឹកដែលត្រូវការពាររួមមាន៖ ត្រែង រៃ ត្រស់ រាំង ទន្លា | • ប្រជុំផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក (ស្ត្រីជាគណៈកម្មការសហគមន៍នេសាទចូលរួមផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក ការពារព្រៃលិចទឹក និងដាក់ស្លាកសញ្ញាសម្គាល់)<br>• ការពារព្រៃលិចទឹកដែលមានស្រាប់<br>• ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក និងស្លាកសញ្ញាសម្គាល់<br>• ដាំព្រៃលិចទឹក<br>• ចុះល្បាតជាប្រចាំ | ៣០០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |

## ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

### ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៣០ គ្រួសារ (២០ក្បាល/គ្រួសារ) | ៦០០ក្បាលx ៥=៣.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមគោជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៣០ គ្រួសារ (១ក្បាល/គ្រួសារ) | ៣០ក្បាលx ៣០០= ៩.០០០ | | |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៣០ គ្រួសារ (២ក្បាល/គ្រួសារ) | ៦០ក្បាលx ៥០=៣.០០០ | | |
| សួនបន្លែតាមលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសធ្វើសួនបន្លែជាគ្រួសារ<br>• ចែកគ្រាប់ពូជ អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | បន្លែ៥មុខ គឺ ត្រកួន ស្ពៃ ត្រប់ សណ្តែក ល្ពៅ ម្ទេស ផ្សិត ចំបើង | ៣០ គ្រួសារ (គ្រាប់ពូជ ៥ ប្រភេទ/១ គ្រួសារ) | ៣០គ្រួសារx ៥០=១.៥០០ | | |

### ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទ | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|---|
| | | | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាម | • ជ្រើសរើសកសិករស្ម័គ្រចិត្ត | ស្រះទំហំ ២មx៣មx១ម | ត្រីអណ្តែង (៦.០០០កូន) | ១៤០ គ្រួសារ | ១៤០គ្រួសារx ៥០០/ | កក្កដា ២០១៩ | មិថុនា ២០២២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| បច្ចេកទេសជាលក្ខណៈគ្រួសារ | • បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ<br>• រៀបចំស្រះចិញ្ចឹមត្រី<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | | | | គ្រួសារ= ៧០.០០០ | | |

### ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់

ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ពង្រឹងក្រុមសន្សំប្រាក់ដែលមានស្រាប់៥ក្រុម | • ផ្សព្វផ្សាយទស្សនទានក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសសមាជិកអ្នកទទួលផលបន្ថែម<br>• ពិនិត្យនិងកែលំអគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• ផ្តល់ទុនបន្ថែមដល់ក្រុម<br>• តាមដាន និងត្រួតពិនិត្យ | ៥x១០០/ក្រុម=៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ជួសជុលផ្លូវក្រាលគ្រួសក្រហមក្នុងភូមិអូរលុងប្រវែង៦៩០ម៉ែត្រ ទទឹង ៤ម៉ែត្រ | ១ ខ្សែ | ១០.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ជួសជុលផ្លូវក្រាលគ្រួសធម្មជាតិទំនប់ទទឹងថ្ងៃ (២គ.ម) ផ្លូវរៀងវិទ្យាល័យ (១គ.ម) និងស្រែឡៀ(៤,៥គ.ម) ក្នុងភូមិព្រៃកប្រសព្វកណ្តាល | ៣ ខ្សែ | ៥៥.០០០ | | |
| ជួសជុលផ្លូវក្រាលគ្រួសធម្មជាតិទទឹង (២គ.ម) និងក្រោយភូមិព្រៃគួរ (៤គ.ម) | ២ ខ្សែ | ៣០.០០០ | | |
| ជួសជុលផ្លូវក្រាលគ្រួសធម្មជាតិមាត់ទន្លេ (២គ.ម) និងទទឹងភូមិជីដុះក្រោម (១,២គ.ម) | ២ ខ្សែ | ២៨.៧៥០ | | |
| ជួសជុលផ្លូវក្រាលគ្រួសធម្មជាតិទួលដំបងអូរលុង (១គ.ម) និងសាងសង់លូកាត់ផ្លូវ២កន្លែង | ផ្លូវ១ខ្សែ & លូ២កន្លែង | ១១.០០០ | | |
| ជួសជុលផ្លូវក្រាលគ្រួសធម្មជាតិអូរថ្មី (៤គ.ម) អូរសំពោន (២គ.ម) អូរចេក (៤គ.ម) ក្នុងភូមិ (២គ.ម) បឹងលាច | ៤ ខ្សែ | ១២០.០០០ | | |

| | | | | |
|---|---|---|---|---|
| ស្ពានប្រឡាយអូរសំពុងឡើងវិញប្រវែង១.៥០០ម៉ែត្រក្នុងភូមិព្រែកប្រសព្វកណ្ដាល | ១ | ៣០.០០០ | | |
| ជួសជុលលូដោះទឹកឡើងវិញប្រវែង១.៣០០ម៉ែត្រក្នុងភូមិព្រែកប្រសព្វក្រោម | ១ | ១២.៥០០ | | |
| ជីកប្រឡាយអូរលុងប្រវែង៣០០ម៉ែត្រ | ១ | ២០.០០០ | | |
| ស្ពានប្រឡាយបឹងលាចប្រវែង១០០ម៉ែត្រ | ១ | ៧.៥០០ | | |
| សាងសង់ទំនប់ចំម្លងប្រវែង២០ម៉ែត្រក្នុងភូមិបឹងលាច | ១ | ៣.៧៥០ | | |
| សាងសង់អណ្ដូងស្នប់ | ១០ អណ្ដូង | ១០.០០០ | | |
| សាងសង់បង្គន់អនាម័យ | ១៧០ បង្គន់ | ៨៥.០០០ | | |

### ឃ.៣. ការគ្រប់គ្រង

### ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើសត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង (រដូវវស្សា) | | ៤ដង/១ខែ | ៤ដងx៦ខែx៣x ៥០=៣.៦០០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ(រដូវប្រាំង) | | ៦ដង/១ខែ | ៦ដងx៦ខែx៣x ៥០=៥.៤០០ (៣ឆ្នាំ) | វិច្ឆិកា ២០១៩ | មេសា ២០២២ |
| ផ្ដល់សម្ភារល្បាត (១ ឈុត) | អាវពោង | ១២ អាវ | ១.០០០ | កក្កដា ២០១៩ | កញ្ញា ២០១៩ |
| | អាវភ្លៀង | ១២ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ២ គោម | | | |
| | វិទ្យុទាក់ទង | ២ គ្រឿង | | | |
| | កែវយឺត | ២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ២ គ្រឿង | | | |
| | អង្រឹង | ១២ | | | |
| | តង់គ្របទូក ៤មគុណ៦ម | ១ | | | |
| | សម្ភារត្រួតពិនិត្យទឹក | ១គ្រឿង | | | |
| | ស្លាបចក្រ | ៦គ្រឿង | | | |
| | សោរឈុតសម្រាប់ជួសជុលទូក | ១សម្រាប់ | | | |
| | សោរច្រវាក់ចាក់ទូក | ២ | | | |

| | | | | | |
|---|---|---|---|---|---|
| | អាវយឺត | ២៤ | | | |
| ទិញទូកស្ពាច់ម៉ាស៊ីន | | ២ គ្រឿង | ៣.០០០ | | |
| ប្រេងសម្រាប់ល្បាត | | ១០០ លីត្រ/ខែ | ១០០លីត្រx៣៦ខែx១=៣.៦០០ (៣ឆ្នាំ) | តុលា ២០១៩ | មិថុនា ២០២២ |
| សេវាជួសជុលនិងថែទាំទូកនិងម៉ាស៊ីន | | ២ដង/ឆ្នាំ | ៦ដងx១០០=៦០០ (៣ឆ្នាំ) | | |
| សាងសង់ទីស្នាក់ការសហគមន៍ | | ១ កន្លែង | ៣.០០០ | កក្កដា ២០១៩ | កញ្ញា ២០១៩ |

### ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោមៈ

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ៣៦ដងx១០=៣៦០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ៣៦ដងx១០=៣៦០ (៣ឆ្នាំ) | | |
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ និងការរៀបចំទុកដាក់ឯកសារ | ១លើក/១ឆ្នាំ | ៣លើកx២០=៦០ (៣ឆ្នាំ) | | |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ១លើក/១ឆ្នាំ | ៣លើកx២០=៦០ (៣ឆ្នាំ) | | |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១លើក/១ឆ្នាំ | ៣លើកx២០=៦០ (៣ឆ្នាំ) | | |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | ១លើក/១ឆ្នាំ | ៣លើកx២០=៦០ (៣ឆ្នាំ) | | |
| បណ្តុះបណ្តាលអំពីការកត់ត្រាចំណាយចំណូល | ១លើក/១ឆ្នាំ | ៣លើកx២០=៦០ (៣ឆ្នាំ) | | |
| បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | ១លើក/១ឆ្នាំ | ៣លើកx២០=៦០ (៣ឆ្នាំ) | | |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោមៈ

| ផែនការ | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| បង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ៦ដងx២៥=១៥០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ | ១ដង/ឆ្នាំ | ៣ដងx២៥=៧៥ (៣ឆ្នាំ) | | |

| | | | | | |
|---|---|---|---|---|---|
| | ផ្សព្វផ្សាយផែននេសាទ និងកន្លែងអភិរក្សរបស់សហគមន៍ | ១ដង/ឆ្នាំ | ៣ដងx២៥=៧៥ (៣ឆ្នាំ) | | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ១ដង/ឆ្នាំ | ៣ដងx១០=៣០ (៣ឆ្នាំ) | | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ | ១ដង/ឆ្នាំ | ៣ដងx២៥=៧៥ (៣ឆ្នាំ) | | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ | ៣ដងx១០០= ៣០០ (៣ឆ្នាំ) | | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាព និងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ | ៣ដងx២៥=៧៥ (៣ឆ្នាំ) | | |

### ឃ.៣.៤ ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ៣លើកx៥០=១៥០ (១លើក/ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មាការសហគមន៍នេសាទ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៣លើកx១០=៣០ (១លើក/ឆ្នាំ) | | | គណៈកម្មាការសហគមន៍នេសាទ |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | កក្កដា ២០១៩ | មិថុនា ២០២២ | ២៣,៦២ | ៥០០រៀល/នាក់ (១៨៩នាក់) |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | | | ២៧៧,៥០ | ៦.០០០រៀល/គ្រួសារ/ឆ្នាំ (១៨៥គ្រួសារ) |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ៖<br>-អំណោយពីរាជរដ្ឋាភិបាល<br>-អំណោយពីសប្បុរសជន<br>-ជំនួយពីអង្គការជាតិ និងអង្គការដៃគូនានា | • ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | | | ៥៤០.៦០៩ | -ចំណាយ ៥៤០.៩១០ដុល្លារ<br>-ចំណូល ៣០១ដុល្លារ |

## ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ១២ដងx១០= ១២០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការសហគមន៍នេសាទ |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | ៣ដងx២០០= ៦០០ (៣ឆ្នាំ) | | | គណៈកម្មការសហគមន៍នេសាទ |

## ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា៖ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ក្នុងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគឃុំ

- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទ ចូលរួមយ៉ាងតិច ៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីជាសមាជិកសហគមន៍នេសាទ  ៤០% ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច
- ជ្រើសរើសស្ត្រី៥០%ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព ក្នុងនោះស្ត្រីជាមេគ្រួសារ ៧%
- ផ្តល់ឱកាសដល់ស្ត្រីនៃអ្នកទទួលផលសរុបទទួលបានផលប្រយោជន៍ពីគម្រោង
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្ត និងពង្រឹងការប្តេជ្ញាចិត្តរបស់ស្ត្រី ដើម្បីធានាថាស្ត្រីជាសមាជិកគណៈកម្មការសហគមន៍នេសាទមិនបោះបង់ការងារសហគមន៍
- រៀបចំការប្រជុំឱ្យស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម
- ជំរុញឱ្យមានស្ត្រីយ៉ាងតិច២៥% ជាសមាជិកគណៈកម្មការសហគមន៍នេសាទ។

## តារាងសង្ខេបផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍អូរលុង រយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| **ឃ.១. ធនធានជលផល និងអេកូឡូស៊ី** | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ ២ ដង ក្នុង០១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ១៥០ (៥០/១ឆ្នាំ) | អង្គការដៃគូ រដ្ឋបាលជលផល ថវិកាសហគមន៍ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ | ដាក់ពោង ស្លាកសញ្ញាសំគាល់កន្លែងអភិរក្ស និងលូសិប្បនិម្មិត | ពោង និងលូសិប្បនិម្មិតចំនួន ៣០០ ត្រូវបានដាក់ ហើយស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៤ ស្លាកត្រូវបានតម្លើង | ៣.០០០ (៣០០x១០) | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | ធ្នូ ២០១៩ | |
| | តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស | ផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្សចំនួន ២ ផ្ទាំងត្រូវបានតម្លើង | ៤០០ | | វិច្ឆិកា ២០១៩ | ធ្នូ ២០១៩ | |
| | លែងកូនត្រីពូជ | កូនត្រីពូជរួមមាន៖ ត្រីខ្លា ត្រីឆ្ពិន ត្រីប្រា ត្រីខ្យា ត្រីឆ្តោក ត្រីគល់រាំង ត្រីត្រសក់ ត្រូវបានលែងចូលក្នុងអន្លង់ | ១.៥០០ (១ដងx៣ឆ្នាំx៥០០) | | កក្កដា ២០១៩ | កក្កដា ២០២១ | |
| ឃ.១.៣. ផែនការបោះបង្គោលព្រំ | បោះបង្គោលព្រំប្រទល់កន្លែងនេសាទលើគោក | បង្គោលព្រំចំនួន ៦បង្គោលត្រូវបានបោះ | ១.៨០០ (៦x៣០០) | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | ធ្នូ ២០១៩ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | ផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍១ផ្ទាំងត្រូវបានតម្លើង | ៣០០ | | តុលា ២០១៩ | ធ្នូ ២០១៩ | |
| ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាំ និងរក្សាការពារព្រៃលិចទឹកនៅជុំវិញបឹងផ្គាំ និងបឹងផ្កា | ព្រៃលិចទឹកដែលត្រូវការពារព្រមទាំងដាំឡើង រួមមានៈ ត្រែង រ៉ៃ ត្រស់ រាំង ទន្លា | ៣០០ (៣ឆ្នាំx១០០) | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ៣០ គ្រួសារចេះបច្ចេកទេសចិញ្ចឹមមាន់ និងអាចលក់រកប្រាក់ចំណូលបន្ថែម | ៣.០០០ (៦០០ក្បាលx៥) | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | មិថុនា ២០២២ | ២០ក្បាល/១ គ្រួសារ |
